ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ:.....៤០១១..... PC.អក

សេចក្តីជូនដំណឹង
ស្តីពី

ការអនុវត្តនីតិវិធីដេញថ្លៃ ពិគ្រោះថ្លៃ និងដេញថ្លៃមានកម្រិត តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសំឡេងដោយផ្ទាល់ (Zoom Meeting) ក្នុងករណីមានការរីករាលដាលនៃជំងឺកូវីដ-១៩ និងករណីចាំបាច់ផ្សេងៗ

អគ្គិសនីកម្ពុជា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុង ព្រះរាជាណាចក្រកម្ពុជា ឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជានឹងរៀបចំអនុវត្តនីតិវិធីដេញថ្លៃ ពិគ្រោះថ្លៃ និងដេញថ្លៃមានកម្រិត តាមរយៈប្រព័ន្ធបញ្ជូនរូបភាពនិងសំឡេងដោយផ្ទាល់ (Zoom Meeting) ដើម្បីចូលរួមជួយកាត់បន្ថយការរីករាលដាលនៃជំងឺកូវីដ-១៩ និងករណីចាំបាច់ផ្សេងៗ ដែលតម្រូវឲ្យបណ្តាក្រុមហ៊ុន/សហគ្រាសទាំងអស់ដែលមានបំណងចង់ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ និងដេញថ្លៃមានកម្រិត អនុវត្តតាមការណែនាំដូចខាងក្រោម ៖

I. ការទំនាក់ទំនងដើម្បីទទួលបានឯកសារ

ក្រុមហ៊ុន/សហគ្រាស ដែលមានចំណាប់អារម្មណ៍លើគម្រោងដេញថ្លៃ ពិគ្រោះថ្លៃ និងដេញថ្លៃមានកម្រិតណាមួយនោះក្រុមហ៊ុន/សហគ្រាស អាចមកទំនាក់ទំនង ដើម្បីទិញឯកសារដេញថ្លៃដោយផ្ទាល់ ឬ តាមរយៈលេខទូរស័ព្ទ (023 676 6007 / 092 652 357) ។ អគ្គិសនីកម្ពុជានឹងផ្តល់ដោយផ្ទាល់ ឬបញ្ជូនសៀវភៅបន្ទុកដេញថ្លៃ ឬពិគ្រោះថ្លៃ និងឯកសារដេញថ្លៃមានកម្រិត ជាលក្ខណៈ Soft Copy ដែលនឹងផ្ញើទៅក្រុមហ៊ុនតាមរយៈ Email ផ្លូវការរបស់អង្គភាពលទ្ធកម្ម នៃអគ្គិសនីកម្ពុជា (edcprocurementdep@gmail.com) ដែលមានកំណត់ពេលវេលាជាក់លាក់ក្នុងឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងដេញថ្លៃមានកម្រិត ។

II. បែបបទរៀបចំឯកសារ និងដាក់ឯកសារ

ក្រុមហ៊ុនត្រូវរៀបចំឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងដេញថ្លៃមានកម្រិតតាមការកំណត់នៅក្នុងសៀវភៅបន្ទុករួចត្រូវរៀបចំ Scan ឯកសារនោះ ជាពណ៌ធម្មជាតិ រួចរៀបចំដាក់ជាប្រភេទ File Zip ដោយភ្ជាប់ជាមួយលេខសម្ងាត់ (Password) រៀងៗខ្លួន រួចផ្ញើត្រឡប់មកអង្គភាពលទ្ធកម្មតាមរយៈ Email ផ្លូវការ របស់អង្គភាពលទ្ធកម្ម តាមពេលវេលាកំណត់ ហើយក្រុមហ៊ុនត្រូវរក្សាលេខសម្ងាត់ ដោយខ្លួនឯងរហូតដល់ថ្ងៃបើកឯកសារ ។

(បញ្ជាក់ឯកសារ ដែល Scan នោះត្រូវសន្មតថាជាឯកសារផ្លូវការស្របច្បាប់)
(ជូនភ្ជាប់ជាមួយ នឹងរបៀបរៀបចំឯកសារ)

III. ការបើកឯកសារ

ការបើកឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងដេញថ្លៃមានកម្រិតត្រូវរៀបចំឡើងតាមរយៈ Video Conference (Zoom) ដែលក្រុមហ៊ុនត្រូវចូលរួមពីចម្ងាយ តាមរយៈកម្មវិធី Zoom ។ នៅពេលការប្រជុំបើកឯកសារដេញថ្លៃ ក្រុមហ៊ុន ត្រូវផ្តល់លេខសម្ងាត់មកក្រុមការងារអង្គភាពលទ្ធកម្ម ដើម្បីអាចបើក File ឯកសារដេញថ្លៃរបស់ក្រុមហ៊ុនបាន ។ ចំណែកឯនីតិវិធីបន្តទៀត (ការវាយតម្លៃឯកសារដេញថ្លៃ) គឺនៅរក្សាការអនុវត្តដូចធម្មតា ។

<u>បញ្ជាក់ ៖ ករណី File ឯកសារ មិនអាចបើកបាន ឬលេខសម្ងាត់មិនត្រឹមត្រូវ ដូចនេះការចូលរួមរបស់ក្រុមហ៊ុន ចាត់ទុកជាមោយៈ ។</u>

IV. ប្រាក់កក់ធានាការដេញថ្លៃ (២%)

ក្រុមហ៊ុនមានជម្រើសចំនួន ០៣ ដូចខាងក្រោម ៖

1. ក្រុមហ៊ុនអាចផ្ទេរប្រាក់ចូលគណនីតាមធនាគាររបស់អគ្គិសនីកម្ពុជា រួចផ្ញើ Bank Slip មកកាន់ E-mail : vechakloeung@edc.com.kh មុនថ្ងៃដេញថ្លៃ ០១ ថ្ងៃ ដើម្បីនាយកដ្ឋានគណនេយ្យធ្វើការផ្ទៀងផ្ទាត់ នឹងរៀបចំប័ណ្ណចំណូល (ប្រាក់កក់ធានាការដេញថ្លៃ ២%) ជូនក្រុមហ៊ុនវិញ ហើយក្រុមហ៊ុនត្រូវភ្ជាប់ Bank Slip និងប័ណ្ណចំណូលនេះជា **Soft Copy** ក្នុងឯកសារដេញថ្លៃមកកាន់អង្គភាពលទ្ធកម្ម ។

   (ជូនភ្ជាប់ជាមួយគណនីរបស់អគ្គិសនីកម្ពុជានៅតាមបណ្តាធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ)

2. ក្រុមហ៊ុនអាចផ្ញើលិខិតធានា (Bank Guarantee) Scan Original Copy ភ្ជាប់ក្នុងឯកសារដេញថ្លៃមកអង្គភាពលទ្ធកម្ម ។ ១ថ្ងៃ ក្រោយការបើកឯកសារដេញថ្លៃ ក្រុមហ៊ុនត្រូវប្រគល់លិខិតធានាច្បាប់ដើម និងឯកសារដេញថ្លៃច្បាប់ដើមមក គណៈកម្មាធិការលទ្ធកម្មជាចាំបាច់ ទោះបីជាលទ្ធផលដេញថ្លៃនេះក្រុមហ៊ុនជាប់ឬធ្លាក់ក៏ដោយ ។ លិខិតធានាត្រូវធ្វើនៅធនាគារពាណិជ្ជ ដែលបានចុះអនុស្សារណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមមាន ៖ (១) ធនាគារ អេស៊ីលីដា ភីអិលស៊ី (២) ធនាគារ កាណា ឌីយ៉ា កអ (៣) ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (៤) ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី (៥) ធនាគារ វឌ្ឍនៈ (Vattanac Bank) (៦) ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ (ABA) (៧) ធនាគារ ស៊ីអាយអិមបឺ ភីអិលស៊ី (CIMB BANK) (៨). ធនាគារ មេយ បើង (ខេមបូឌា) ភីអិលស៊ី និង (៩). ធនាគារ ដេ ត្រាស់ រ៉ូយ៉ាល់ ។

3. ក្រុមហ៊ុនអាចធ្វើជា មូលប្បទានបត្រមានការធានា (Certified Check) របស់ធនាគារពាណិជ្ជណាមួយដែលបានចុះអនុស្សារណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រី ជ្រាបជាព័ត៌មាន តាមការគួរ។

ថ្ងៃ ៤ ១០៣៤ ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០២១

ប្រធានគណៈកម្មាធិការលទ្ធកម្ម

ហាង់-ឆូម

គណនីរបស់អគ្គិសនីកម្ពុជា នៅតាមបណ្តាធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

១. ធនាគារ អេស៊ីលីដា ភីអិលស៊ី	លេខគណនី: 0001-10-583555-1-5 ។
២. ធនាគារ កាណាឌីយ៉ា ក.អ	លេខគណនី: 0010000061277 ។
៣. ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា	លេខគណនី: 300001284887 ។
៤. ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី	លេខគណនី: 010.02.10.09292.2 ។
៥. ធនាគារ វឌ្ឍនៈ	លេខគណនី: 010.02.88.000019.9 ។
៦. ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់	លេខគណនី: 000183812 ។
៧. ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី	លេខគណនី: 1010121000029978 ។
៨. ធនាគារ មេយ ប៊ែង (ខេមបូឌា) ភីអិលស៊ី	លេខគណនី: 00001/02/004202/07 ។
៩. ធនាគារ ដេ ត្រាស់ រ៉ូយ៉ាល់	លេខគណនី: 1719081 ។
១០. ធនាគារ ហ្វីលីព	លេខគណនី: 000003434 ។
១១. ធនាគារ ប្រេដ	លេខគណនី: 001001098900018 ។
១២. ធនាគារ ភីភីស៊ីប៊ែង	លេខគណនី: 1110000045320 ។
១៣. ធនាគារ ជីប ម៉ុង	លេខគណនី: 13313333 ។
១៤. ធនាគារ ចិន	លេខគណនី: 100001100760219 ។
១៥. ធនាគារ ស្ថាបនា	លេខគណនី: 09906469112600102 ។
១៦. ធនាគារ កាថេយូណៃធីត(កម្ពុជា)ចំកាត់	លេខគណនី: 01120210032455 ។
១៧. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ	លេខគណនី:51497837 ។
១៨. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់	លេខគណនី: 00519469-002-4 ។

របៀបនៃការបង្កើត File Zip



File ដែលបាន Scan រួច ត្រូវចុច Mouse ស្តាំ រួចរើសយកពាក្យ “WinRAR” បន្ទាប់មក “Add to archive…”



បន្ទាប់ពីផ្ទាំងបានបើក ត្រូវកំណត់ Archive format ជាប្រភេទ ZIP និងចុចលើពាក្យ “Set Password”



ក្រុមហ៊ុនត្រូវកំណត់លេខសម្ងាត់ (Password) និងត្រូវរក្សាទុករហូតដល់ថ្ងៃបើកឯកសារ បន្ទាប់មកចុច OK



បន្ទាប់ពីចុច “OK” រួចមក File ZIP នឹងត្រូវបង្កើតឡើង ដោយភ្ជាប់ជាមួយលេខសម្ងាត់។ ក្រុមហ៊ុនត្រូវផ្ញើ File ZIP នោះមកអគ្គិសនីកម្ពុជាតាមរយៈ Email ខាងលើ។

បែបបទក្នុងការរៀបចំឯកសារ ដាក់ក្នុងឯកសារដេញថ្លៃ/ពិគ្រោះថ្លៃ និងដេញថ្លៃមានកម្រិត

ដើម្បីបង្កភាពលក្ខណៈងាយស្រួលដល់ក្រុមការងារនៅក្នុងពេលបើក ឯកសារដេញថ្លៃ / ពិគ្រោះថ្លៃ / ដេញថ្លៃមានកម្រិត សូមលោក/ លោកស្រី រៀបចំ SCAN ឯកសារជាពណ៌ធម្មជាតិ (SCAN Color) តាមលំដាប់លំដោយ ដូចខាងក្រោម ៖

សូមក្រុមហ៊ុនដាក់ ឈ្មោះ (Rename The FILE ZIP) ជាឈ្មោះក្រុមហ៊ុន និងលេខកូដ នៃគម្រោងនោះ ដែលក្នុង FILE ZIP មានឯកសារ SCAN ទី១ (PDFទី១) និង ឯកសារ SCAN ទី២ (PDFទី២)។

ក - ឯកសារដេញថ្លៃ / ពិគ្រោះថ្លៃ / ដេញថ្លៃមានកម្រិត ជាប្រភេទទំនិញ ៖

I. ឯកសារ SCAN ទី១ (PDFទី១)

1- ពាក្យសុំដេញថ្លៃ
2- តារាងតម្លៃ
3- លិខិតប្រាក់កក់ធានាការដេញថ្លៃ
4- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន
5- ប័ណ្ណប៉ាតង់ឆ្នាំដេញថ្លៃ
6- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម អ.ត.ប (VAT Certificate)
7- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
8- ច្បាប់អនុញ្ញាតឲ្យធ្វើអាជីវកម្មចេញដោយក្រសួងជំនាញពាក់ព័ន្ធ (ប្រសិនបើមាន)

II. ឯកសារ SCAN ទី២ (PDFទី២)

9- ឯកសារកស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាព "ហិរញ្ញវត្ថុ បច្ចេកទេស បទពិសោធន៍ "
10- ឯកសារយោងផ្សេងៗ

ខ - ឯកសារដេញថ្លៃ / ពិគ្រោះថ្លៃ / ដេញថ្លៃមានកម្រិត ជាប្រភេទសំណង់ ៖

I. ឯកសារ SCAN ទី១ (PDFទី១)

1- ពាក្យសុំដេញថ្លៃ
2- តារាងតម្លៃ
3- លិខិតប្រាក់កក់ធានាការដេញថ្លៃ
4- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន
5- ប័ណ្ណប៉ាតង់ឆ្នាំដេញថ្លៃ
6- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម អ.ត.ប (VAT Certificate)
7- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
8- វិញ្ញាបនប័ត្រប្រកបអាជីវកម្មចេញដោយក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់
9- វិញ្ញាបនប័ត្រចុះបញ្ជីអ្នកទទួលការសាងសង់ចេញដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

II. ឯកសារ SCAN ទី២ (PDFទី២)

10- ឯកសារកស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាព "ហិរញ្ញវត្ថុ បច្ចេកទេស បទពិសោធន៍ "
11- ឯកសារយោងផ្សេងៗ

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រី ជ្រាបជាព័ត៌មាន តាមការគួរ ។